**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ...០៧៥...ស.ជ.ណ

ថ្ងៃ.អង្គារ..០៩កើត...ខែពិសាខ.ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២០......ខែមេសា..ឆ្នាំ២០២១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យាពេលបើកឯកសារដេញថ្លៃ

យោងតាមសេចក្តីសម្រេចលេខ៥០សសរ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ ស្តីពីការកែសម្រួលវិធានការដែលត្រូវអនុវត្តក្នុងអំឡុងពេលបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមប្រកាសពន្យាពេលបើកឯកសារដេញថ្លៃ ដូចខាងក្រោម៖

ក-ផ្គត់ផ្គង់គ្រឿងបន្លាស់ប្រព័ន្ធផលិតកម្ម ស៊ីម៉ង់ត៍ សម្ភារតភ្ជាប់សម្រាប់ជួសជុលបំពង់ប៉េអឺ និងបរិក្ខារ SERVER គ្រោងនឹងបើកឯកសារដេញថ្លៃនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១ (សេចក្តីជូនដំណឹងលេខ០៥១ស.ជ.ណ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១)

ខ-ផ្គត់ផ្គង់បំពង់ជ័រប៉េអឺ និងសម្ភារតភ្ជាប់ប៉េអឺ គ្រោងនឹងបើកឯកសារដេញថ្លៃនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ (សេចក្តីជូនដំណឹងលេខ០៣០ស.ជ.ណ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១)

គ-ផ្គត់ផ្គង់នាឡិកាទឹកមេកានិច-ខ្នាតតូច គ្រោងនឹងបើកឯកសារដេញថ្លៃនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១ (សេចក្តីជូនដំណឹងលេខ០១៩ស.ជ.ណ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១)

ឃ-ផ្គត់ផ្គង់ខ្សាច់ទន្លេ គ្រោងនឹងបើកឯកសារដេញថ្លៃនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ (សេចក្តីជូនដំណឹងលេខ០២៥ ស.ជ.ណ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១)

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងជូនដំណឹងពីកាលបរិច្ឆេទបើកឯកសារដេញថ្លៃឡើងវិញ បន្ទាប់ពីមានសេចក្តីសម្រេចថ្មីពីរាជរដ្ឋាភិបាល។

សូមលោក លោកស្រីប្រធានក្រុមហ៊ុន/សហគ្រាស មេត្តាអធ្យាស្រ័យ ដោយអនុគ្រោះ។

**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានទី១**

**ម៉ា.ណូវ៉ាទីន**

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ